# ប្រកាសព័ត៌មាន លេខ ២២ (ខែ មករា ឆ្នាំ ២០១៦)

ចាប់តាំងពីដើមខែ មករា ឆ្នាំ ២០១៦ ប្រព័ន្ធ FMIS បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការដល់រតនាគាររាជធានី-ខេត្ត ចំនួន ១៦ ដោយផ្តោតសំខាន់លើមុខងារសំខាន់ចំនួន ៥ ។ ក្នុងការដាក់ឱ្យប្រើប្រាស់នេះ ក្រុមការងារគម្រោង FMIS របស់នាយកដ្ឋានព័ត៌មានវិទ្យាបានចុះជួយផ្ទាល់ដើម្បីគាំទ្រ និង បង្ហាត់បង្រៀនបន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធដល់អ្នកប្រើប្រាស់នៅតាមរតនាគារនីមួយៗ ធ្វើយ៉ាងណាឱ្យអ្នកប្រើប្រាស់ទាំងអស់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារប្រចាំថ្ងៃជាមួយប្រព័ន្ធ FMIS ដោយទទួលបានការគាំទ្រយ៉ាងខ្លាំង ។ ទន្ទឹមនឹងនេះ ក្រុមការងារនីតិវិធីអនុវត្តស្តង់ដារកំពុងពិនិត្យលម្អិតឡើងវិញលើឯកសារនីតិវិធីអនុវត្តស្តង់ដារ (Standard Operating Procedures) ចាប់ពីការស្នើសុំធានាចំណាយរហូតដល់ការទូទាត់ចំណាយ (Procure to Pay Processes) មុននឹងដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យ សម្រេច និង អនុម័ត ដើម្បីប្រកាសដាក់ឱ្យអគ្គនាយកដ្ឋាន- នាយកដ្ឋានពាក់ព័ន្ធគន្លឹះអនុវត្តតាម សម្រាប់ជាជំនួយដល់ការអនុវត្តការងារប្រចាំថ្ងៃ និង ជាមូលដ្ឋានគ្រឹះក្នុងការបន្តរៀបចំនីតិវិធីអនុវត្តការងារដែលនៅសេសសល់ ។

ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាកំពុងខិតខំបញ្ចប់ការងារពាក់ព័ន្ធនឹងការធ្វើសន្ធានកម្មជាមួយប្រព័ន្ធ ASYCUDA និង ប្រព័ន្ធ Payroll ដោយត្រូវដោះស្រាយបញ្ហាបច្ចេកទេសមួយចំនួនដែលនៅសេសសល់ ក្នុងការដាក់ឱ្យដំណើរការមុខងារសន្ធានកម្មជាមួយប្រព័ន្ធ FMIS ។ ក្រុមការងារគ្រប់គ្រងការផ្លាស់កំពុងបន្តអនុវត្តការផ្សព្វផ្សាយអំពីវឌ្ឍនភាពតាមរយៈ ការទំនាក់ទំនងផ្សព្វផ្សាយផ្ទាល់, តាមគេហទំព័រ, កិច្ចប្រជុំផ្សេងៗ, និង ព្រឹត្តិការណ៍នានា ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមអំពីប្រព័ន្ធ FMIS កាន់តែជាក់ច្បាស់ ពិសេសអំពីសារៈប្រយោជន៍ដែលអ្នកប្រើប្រាស់ និង អ្នកពាក់ព័ន្ធនឹងទទួលបាន ។ ជាមួយគ្នានេះ មន្ត្រីភ្នាក់ងារផ្លាស់ប្តូរតាមបណ្តារតនាគាររាជធានី-ខេត្តនីមួយៗ បាននិងកំពុងដើរតួយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយ គាំទ្រ ជំរុញ និង លើកកម្ពស់ការយល់ដឹងអំពីប្រព័ន្ធ FMIS ជូនដល់អ្នកប្រើប្រាស់ប្រព័ន្ធនៅក្នុងអង្គភាពរបស់ខ្លួនផ្ទាល់ ។

ក្រុមការងារផ្នែកបណ្តុះបណ្តាលកំពុងត្រៀមរៀបចំវគ្គបណ្តុះបណ្តាលជូនអ្នកប្រើប្រាស់ប្រព័ន្ធសម្រាប់រតនាគាររាជធានី-ខេត្តចំនួន ៩ ដែលត្រូវដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ខាងមុខនេះ ។ ចំណែកក្រុមការងារហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍បន្តចុះបេសកកម្មតាមរតនាគារខេត្តដើម្បីដំឡើងម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនព្រីន និង ម៉ាស៊ីនស្កេន ដែលនឹងបញ្ចប់កំឡុងខែ កុម្ភៈ ។




សម្រាប់ព័ត៌មានបន្ថែមផ្សេងៗ សូមចូលទៅកាន់គេហទំព័រ ឬទំនាក់ទំនងតាមអ៊ីមែល ឬទូរស័ព្ទដូចខាងក្រោម÷
គេហទំព័រ÷ http://fmis.mef.gov.kh អ៊ីមែល÷ fmis.info@mef.gov.kh ទូរស័ព្ទទំនាក់ទំនង÷ 023 430 063